# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

---

តុលាការខេត្តកំពង់ធំ

សំណុំរឿង

លេខ : ១៦៣ ចុះថ្ងៃទី ២២

ខែ ឧសភា ឆ្នាំ ២០០១

សាលក្រម

លេខ : ៦៩ "ក" ចុះថ្ងៃទី ២៨

ខែ តុលា ឆ្នាំ ២០០៥

---

### គាងនាមប្រជារាស្ត្រខ្មែរ
### តុលាការខេត្តកំពង់ធំ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តកំពង់ធំ នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៥ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted]

**តំណាងអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**មេធាវីការពារឱ្យជនជាប់ចោទ**

លោក [redacted]

សាលក្រមនេះចូលស្ថាពរ កាលពីថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៦ តទៅ ដោយគ្មានភាគីណាមួយប្តឹងតវ៉ាតាមកំណត់ច្បាប់ ។
កំពង់ធំ.ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៦
ក្រឡាបញ្ជីតុលាការខេត្ត [redacted]

**ដើម្បីជំនុំជំរះ**

លើជនជាប់ចោទឈ្មោះ ស ៩ ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ កើតនិងរស់នៅភូមិត្រពាំងក្រោល ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ សាសនាព្រះពុទ្ធ របររកស៊ីធ្វើស្រែ ឪពុកឈ្មោះ ស ស (រ) ម្តាយឈ្មោះ ខ ផ (រ) ទោសពីមុនគ្មាន ។ ជាប់ចោទពីបទ បង្ករបួសស្នាមដោយចេតនាមានអាវុធ ។ ប្រព្រឹត្តនៅចំណុចសាលាពពេល ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ កាលពីថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០០ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ : ៦៣២ អក ២០០២ ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៣ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តកំពង់ធំ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១២៣៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៣ របស់ចៅក្រមស៊ើបសួរ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ : ១២៣៨ ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០០៣ របស់តុលាការខេត្តកំពង់ធំ ។



Scanned with CamScanner

## ការប្រព្រឹត្តិរបស់ជនជាប់ចោទ

កាលពីល្ងាចថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០០ ឈ្មោះ ខ សគ និង ឈ្មោះ ស ផ មានការឈ្លោះប្រកែកគ្នាពីរឿងចង្កៀងគ្មានប្រេង ក៏ឈ្មោះ ស ផ ទាញខ្សែក្រវ៉ាត់វាយត្រូវកំភួនជើងប្រពន្ធមួយខ្សែក្រវ៉ាត រួចហើយប្រពន្ធក៏បានទៅផ្ទះឪពុកបាត់ទៅ ។ ព្រឹកឡើងបិតស្រាឪពុកម្តាយខាងក្មេកមកដល់សួរនាំពីរឿងឈ្លោះគ្នា ស្រប ពេលនោះដែរឈ្មោះ ស ផ ជាបងរបស់ឈ្មោះ ស ផ នៅជិតនោះដែរ កកើតរឿងប្រកែកគ្នារវាងឈ្មោះ ស ផ និង ខ សគ ទើបឈ្មោះ ស ផ្ទ អត់ទ្រាំមិនបានទាញចបជីកវាយក្បាល ខ សគ បណ្តាលឱ្យមានរបួសស្នាមទៅ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ ស ៩ គេចខ្លួនមានសវតាជាតិ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ខ សគ បានឆ្លើយថា : មុនដំបូងថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០០ គឺមានរឿងឈ្លោះប្រកែកគ្នាបន្តិចបន្តួចជាមួយ ដោយល្ងាចនោះខ្លួនមកពីធ្វើផ្ទះឱ្យមិត្តភក្តិរកបាយហូប រកចង្កៀងអុជគ្មានប្រេង ហើយហៅប្រពន្ធសួរនាំរកប្រេងចាក់ដាក់ចង្កៀងអុជ ស្រាប់តែប្រពន្ធឆ្លើយថា ដើរលេងឯងមិតចេះបាន ខ្លួនថា ខ្លួនជាមេផ្ទះដឹងអ្វីមាន ដឹងអ្វីឬអត់ បើអត់ចង្កៀងមួយយប់មិនបាន ខ្លួនតបទៅវិញ បើមានលុយទិញម្សៅលាបចេះបាន បើទិញប្រេង ១០០រៀលគ្មាន ។ ពេលនោះខ្លួនខឹងប្រពន្ធពេកទាញខ្សែក្រវ៉ាត់វាយប្រពន្ធមួយខ្សែក្រវ៉ាត់ចំកំភួនជើងរួចចុះមកជីបាត់រហូត ឯខ្លួនអស់កំលាំងផង ក៏បានដេកលក់ទៅ ។ លុះព្រឹកឡើងថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០០ ខ្លួនកំពុងរៀបចំបិតស្រា ស្រាប់តែឃើញឪពុកម្តាយក្មេក និង បងថ្លៃមករករឿងខ្លួន តែគ្មានកាន់អ្វីទេ ។ មកដល់ឪពុកម្តាយក្មេករករឿងវាយកូនគាត់ ខ្លួនតបវិញថា ពុំបានរករឿងអ្វីខ្លាំងទេ ខ្លួនគ្រាន់តែរកប្រេងចង្កៀងអុជហូបបាយ ប្រពន្ធខ្លួនតមាត់ដាក់ខ្លួន ខ្លួនទ្រាំមិនបានដាក់មួយខ្សែក្រវ៉ាត់ទៅ ។ ឪពុកក្មេកគាត់បានប្រមាថខ្លួនសព្វគ្រប់ ខ្លួនមិនបានតបតទៅវិញទេ ខ្លួនបានដើរចូលទៅរោងស្រា ដោយមានកាន់ក្រណាត់ទៅរុំប៉ោតស្រា កំពុងតែរុំ ស្រាប់តែបងថ្លៃឈ្មោះ ស ៩ បានហៅខ្លួនចេញពីរោងស្រា រួចវាយខ្លួននឹងចបជីកចំក្បាលខាងក្រោយ ខ្លួនសន្លប់តែម្តងមិនដឹងវាយប៉ុន្មានចបជីកទេ រួចហើយបានយកមកព្យាបាលនៅពេទ្យ ដោយឪពុកម្តាយក្មេកបានមកតាមដែរ ។ ចំណែកឈ្មោះ ស ៩ រត់គេចខ្លួនបាត់ ។ ខ្លួនបានដេកព្យាបាលជិតមួយខែ បងថ្លៃបានចេញប្រាក់ឱ្យពេទ្យ ៣០០.០០០រៀល ។ សំណូមពរតុលាការសម្រេចតាមច្បាប់ដោយខ្លួនមិនទាមទារប្រាក់សំណងអ្វីទៀតទេ ។

-សាក្សីឈ្មោះ ស ស ឆ្លើយថា ខ្លួន និង កូនឈ្មោះ ផ ប្តីឈ្មោះ ខ សគ បានរស់នៅឆ្ងាយពីគ្នា ល្ងាចនោះឈ្មោះ ខ សគ និង ប្រពន្ធឈ្មោះ ស ផ ខ្លួនមិនដឹងឈ្លោះប្រកែកគ្នារឿងអ្វីទេ ។ លុះព្រឹកឡើងថ្ងៃខែមិនចាំ ឆ្នាំ ២០០០ ប្រពន្ធខ្លួនទៅរកទិញកន្ទក់ឱ្យជ្រូកស៊ីស្រាប់តែមានមនុស្សមិនស្គាល់មកប្រាប់ថា ឱ្យទៅមើលកូនផង ប្តីវាវាយពោះធំផង អ្នកជិះកង់មកប្រាប់ ទៅបាត់មួយសន្ទុះ ទើបកូនស្រីខ្លួនឈ្មោះ ផ មកដល់ ខ្លួនកំពុងអង្គុយជាមួយប្រពន្ធក្រោមដើមដូង កូនខ្លួនមកដល់និយាយថា ឱ្យខ្លួនទៅនិយាយជាមួយប្តីខ្លួនផង ប្តីខ្លួនវាយខ្លួនជាច្រើនដងមកហើយ ពេលគាត់ផឹក គាត់វាយខ្លួន ខ្លួនក៏បានដេញកូនឱ្យទៅវិញ ។ ពេលនោះខ្លួនជាមួយប្រពន្ធក៏នាំគ្នាទៅផ្ទះកូនម៉ោង ០៧ព្រឹក ពេលទៅដល់ខ្លួនបានសួរនាំវាថា កូនឯងឱ្យតែមកពីផឹកវិញឈ្លោះតែគ្នា តាំងពីល្ងាចរហូតដល់ព្រឹកមិនខ្មាសគេទេកូន អ្នកចេះដឹងអ្វី ធ្វើអីចឹង កូនប្រសារខ្លួនបានឆ្លើយតបមកខ្លួនវិញថា បើឯងបាំយកកូនឯងទៅវិញទៅ ខ្លួនក៏ដើរមកកើត ឈ្មោះ គ នៅឈរពីរោងបិតស្រាវា ២ម ដោយមានកាន់ពូថៅមួយ គ្មានឈរុំអ្វីទេ រួចហើយពេលកូនខ្លួនឈ្មោះ ស ផ មកដល់គ្មានកាន់អ្វីទេ ហើយកូនខ្លួនឈ្មោះ ផ បានឆ្លើយទៅឈ្មោះ គ យកប្អូន

Scanned with CamScanner

អញមកបំភើមហើយ ឯងឱ្យយកទៅវិញ ឈ្មោះ គ បានឆ្លើយថា បើឯងខ្លាំង ឯងស្ទុះមក ភ្លាមនោះឈ្មោះ គ ស្ទុះទៅរកកូនប្រុសខ្លួន ហើយកូនប្រុសខ្លួនស្ទុះទៅយកចបជីក ហើយស្ទុះទៅរកឈ្មោះ គ កូនខ្លួនវាយ ឈ្មោះ គ មុនមួយចបជីកចំក្បាលឈៀងខាងក្រោយប្រហែល ២ម៉ែត្រ ហូរឈាមខ្លាំងមិនសន្លប់ទេ '។ កូនប្រុសខ្លួនរត់គេចខ្លួនបាត់រហូតសព្វថ្ងៃ ។ ឈ្មោះ គ បានរត់រកអ្នកជិតខាងមកជួយសែងទៅពេទ្យ រហូតដល់កូនគាត់ចាក់ថ្នាំឃាត់ឈាម ហើយបានដឹកបន្តមកខេត្ត និងខ្លួនបានដេកកំដរមួយយប់ រហូតស្អែកឡើងបាននគរបាលនាំខ្លួនទៅប៉ុស្តិ៍ ហើយឈ្មោះ គ ដេកពេទ្យបាន ០៧ថ្ងៃ ចេញទៅវិញ ដោយខ្លួនចេញសោហ៊ុយថ្លៃពេទ្យ ៣៧០.០០០រៀល ។

-សាក្សីឈ្មោះ ខ ឆ ឆ្លើយថា : កូនខ្លួនការរួចនៅបែកពីខ្លួនរស់នៅជាមួយប្តីវាចំងាយពីផ្ទះខ្លួន ១គម ។ នៅពេលល្ងាចនោះប្តីប្រពន្ធវាឈ្លោះគ្នា វាយប្រពន្ធវានោះមិនបានដឹងរឿងទេ ។ ព្រឹកឡើងកូនស្រីខ្លួនបានមកប្រាប់ខ្លួន និង ឪពុកវាដែលអង្គុយជាមួយខ្លួនថា ឱ្យជួយទៅមើលប្តីវាផង គាត់មកពីផឹកចេះតែរករឿងខ្លួនជាច្រើនដង ប្រាប់រួចខ្លួនដេញឱ្យទៅផ្ទះវិញដោយកូនស្រីខ្លួនទំងន់ខ្លាតពោះ ហើយមិនដឹងប៉ុន្មានខែទេ តែពេលវាប្រាប់រួចខ្លួនទៅភ្លាមជាមួយឪពុកវា នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០០ ទៅដល់ប្រហែលម៉ោង ០៧ព្រឹក ខ្លួនថា ឱ្យកូនខ្លួន រឿងអីបានល្ហែមល្ហាមម្ល៉េះ កូនប្រាប់ គ វាយខ្លួន កូនឯងមានថា អីឱ្យគេដែរ តែកូនខ្លួនថា មិនមានថា អ្វីទេ វាដេកលក់ប្តីវាវាយទាំងយប់ ខ្លួនមិនបាននិយាយអ្វីតទៅទៀតទេ ប្តីខ្លួនបាននិយាយទៅប្តីវាថា កូនឯងម៉េចបានវាយប្រពន្ធរឿងអី ហេតុអី អង្ករស្រូវម៉ែឱ្យពីណោះមកស្រេច កូនឯងជាអ្នកចេះដឹងដែរ មកពីផឹកវាយប្រពន្ធអីចឹង កូនប្រសារឆ្លើយថា បើហ៎យកកូនឯងទៅវិញ ថារួចឪពុកក្មេកវា និងខ្លួនឃើញវាកាន់ពូថៅនៅដៃឈរចំងាយពីរោងស្រាខាងត្បូងមាត់ទ្វារប្រហែល ២ម ឯប្តី និងខ្លួនដើរចេញពីវាប្រហែល ៤ម ពេលនោះកូនខ្លួនឈ្មោះ ៩ ប្រហែលមកពីចំការដើរមកដល់ ក៏ឆ្លើយទៅវិញថា បើឯងយកប្អូនអញមកបំផើម ហើយឱ្យអញយកទៅវិញ ពេលនោះអា គ មានពូថៅនៅនឹងដៃស្រាប់ស្ទុះទៅវាយអា ៨ ឯងសាកមើលក្បាលស្ទោងមើល កូនខ្លួនក៏ស្ទុះទៅដែរ ស្រាប់តែវាយកចបជីកបានវាយចំក្បាលឈៀងខាងក្រោយមួយចបជីកមិនសន្លប់ទេ ដោយឈាមច្រើន ខ្លួនស្រែកថា ហាក១មិនដឹងយ៉ាងម៉េចទៀត ប្តីខ្លួនមិនបានដេរប្រមាថ នឹងបញ្ចោរ កូនខ្លួនវាយវាក៏គ្មានដែរ ។ ពេលដែលវាត្រូវរបួសភ្លាម ឪពុកវាបានហៅអ្នកជិតខាងឱ្យជួយសែងមកពេទ្យ រហូតដល់ត្នោតបានចាក់ថ្នាំឃាត់ឈាម " រហូតមកដល់ពេទ្យខេត្តព្យាបាលមួយអាទិត្យចេញ បានចេញប្រាក់ព្យាបាលអស់ ៣៧០.០០០រៀល ។ កូនខ្លួនឈ្មោះ ៨ ពេលឈ្លោះគ្នាបានរត់ចេញពីផ្ទះបាត់ ជិតពេលសំរាលកូននៅផ្ទះខ្លួន តែសំរាលកូនបាន ០២ថ្ងៃ ក៏ស្លាប់ទៅ ។

-តំណាងអយ្យការអមតុលាការខេត្តបានសន្និដ្ឋានថា មានពិរុទ្ធភាពចូនល្មមលើឈ្មោះ ស ៩ ភេទប្រុស អាយុ ២៥ឆ្នាំ ពីបទបង្ករបួសស្នាមដោយចេតនាមានអាវុធ ប្រព្រឹត្តនៅភូមិសាលាពពេល ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ កាលពីថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០០ ។ ដូច្នេះអយ្យការសម្រេចតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ៦៣២ ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៣ របស់អយ្យការទុកជាបានការពេញទាំងមូល សុំតុលាការសម្រេចសេចក្តីតាមច្បាប់ ។

-លោក គេខ ខណ្ណារិទ្ធិ មេធាវីការពារឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា ឆ្លងតាមរយៈសវនាការ និង ឯកសារភស្តុតាងឃើញថា អំពើដែលបង្កឡើងបណ្តាលមកពីជនរងគ្រោះ ទើបបានឪពុកម្តាយនាំកូនមកសួរនាំកូនប្រសារ ហើយកូនប្រសារ ខ សគ មានពាក្យសំដីមិនល្អ ជនជាប់ចោទឮសំដីនេះបានចេញមកប្រកែកគ្នាដោយ ខ សគ កាន់ពូថៅ ជនជាប់ចោទកាន់ដំបងប្រតាយគ្នា ក៏ជនជាប់ចោទយកចបជីកបានវាយទៅលើជនរងគ្រោះបណ្តាលឱ្យមានរបួសស្នាមទៅ ។ សំណូមពរតុលាការពិចារណាពីទណ្ឌកម្មដែលជាបទល្មើសមជ្ឈឹម ជនរងគ្រោះ



Scanned with CamScanner

ពិការភាពក្រោម ០៦ខែ ដោយឡែកជនជាប់ចោទបានសាងផ្ទះរួចហើយដែរ សុំតុលាការពិចារណាពីទោសព្យួរ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់ជនជាប់ចោទឆ្លើយជាចុងក្រោយបង្អស់

-ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តកំពង់ធំ

-យល់ឃើញថា : កាលពីល្ងាចថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០០ ឈ្មោះ ខ សគ និង ឈ្មោះ ស ឌ មានការឈ្លោះប្រកែកគ្នាពីរឿងចង្កៀងគ្មានប្រេង ក៏ឈ្មោះ ស ៩ ទាញខ្សែក្រវ៉ាត់វាយត្រូវកំភួនជើងប្រពន្ធមួយខ្សែក្រវ៉ាត់ រួចហើយប្រពន្ធក៏បានទៅផ្ទះឪពុកបាត់ទៅ ។ ព្រឹកឡើងបិតស្រាឪពុកម្តាយក្មេកមកដល់សួរនាំពីរឿងឈ្លោះគ្នា ស្របពេលនោះដែរឈ្មោះ ស ៩ ជាបងរបស់ឈ្មោះ ស ឌ នៅជិតនោះដែរ ក៏កើតរឿងប្រកែកគ្នារវាងឈ្មោះ ស ៩ និង ខ សគ ទើបឈ្មោះ ស ៩ អត់ទ្រាំមិនបានទាញចបជីកវាយក្បាល ខ សគ បណ្តាលឱ្យមានរបួសស្នាមទៅ ។

-យល់ឃើញថា : ជនជាប់ចោទខឹងនឹងជនរងគ្រោះថា ឱ្យឪពុកខ្លួន បើងងហាំយកកូនទៅវិញទៅ ទើបជនជាប់ចោទព្ធ និង ខឹងផងក៏ស្ទុះយកចបជីកវាយទៅលើជនរងគ្រោះនោះ គឺជនជាប់ចោទពិតជាមានចេតនាទុច្ចរិតបង្ករបួសស្នាមទៅលើជនរងគ្រោះដោយអាវុធយ៉ាងពិតប្រាកដ ។

-យល់ឃើញថា អំពើល្មើសនេះមានបញ្ញត្តិច្បាប់ចែងជាបទល្មើសបង្ករបួសស្នាមដោយចេតនាមានអាវុធឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-យល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ស ៩ ពីបទ បង្ករបួសស្នាមដោយចេតនាមានអាវុធប្រព្រឹត្តនៅភូមិសាលាពពេល ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០០ ។

-យល់ឃើញថា ចបជីកដងឈើប្រវែង ៩០សម. បាក់ត្រឹមផ្លែចំនួន ០១ គឺជាសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួនរបស់ជនជាប់ចោទ ។

-យល់ឃើញថា ជនរងគ្រោះមានរបួសស្រាល គឺពិការភាពក្រោម ០៦ខែ ។

-យល់ឃើញថា នាពេលសវនាការនេះដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ខ សគ មិនប្តឹងទាមទារសំណងអ្វីពីជនជាប់ចោទទេ នោះតុលាការមិនលើកយកមកពិចារណាឡើយ ។

## ហេតុដូច្នេះតុលាការខេត្តកំពង់ធំ
## វិនិច្ឆ័យសេចក្តី

១-ផ្តន្ទាទោស : ឈ្មោះ ស ៩ ភេទប្រុស អាយុ ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១ឆ្នាំ តែទោសនេះត្រូវព្យួរសាកល្បងមានរយៈពេល ០៥ឆ្នាំ គិតពីសាលក្រមនេះមានអានុភាពអនុវត្តតទៅ ពីបទ បង្ក



Scanned with CamScanner

របួសស្នាមដោយចេតនាមានអាវុធ ប្រព្រឹត្តនៅភូមិសាលាពពេល ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០០ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៤១ និង ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-វត្ថុតាងមាន : ចបជីកដងឈើប្រវែង ៩០សម បាក់ត្រឹមផ្លែចំនួន ០១ ត្រូវរឹបអូសបំផ្លាញចោល ។

៣-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈកំបាំងមុខជនជាប់ចោទឈ្មោះ ស ៥ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ខ សគ និង មេធាវី ទុកសិទ្ធិប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

| | |
|---|---|
| បានឃើញ | ចៅក្រមជំនុំជំរះ |
| ប្រធានតុលាការខេត្ត | ហត្ថលេខា និង ត្រា |
| [redacted] | [redacted] |

Scanned with CamScanner